# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីបើកវេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ

## នៅវិមានសន្តិភាព ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

***ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ ជាទីមេត្រី !***

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដោយបានមកចូលរួម នៅក្នុងពិធីបើក ***«វេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ»*** នាឱកាសនេះ ។ វេទិកាជាតិនេះ បានប្រារព្ធឡើងតែមួយសប្តាហ៍ មុនសម័យប្រជុំលើកទី ១៩ នៃសន្និសីទភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និង សម័យប្រជុំលើកទី ៩ របស់ភាគីជាសមាជិក **ពិធីសារក្យូតូ** ដែលនឹងប្រព្រឹត្តទៅនៅ **ទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ** ។ ក្នុងន័យនេះ ពិតជាមិនអាចប្រកែកបានទេថា វេទិកាដែលបានរៀបចំឡើងនាពេលនេះ នឹងក្លាយជាធាតុចូលមួយយ៉ាងសំខាន់ ដល់កិចប្រជុំដែលនឹងត្រូវប្រារព្ធឡើង នាពេលខាងមុខ ។ ទន្ទឹមនេះ យើងទាំងអស់គ្នា ក៏ចាំបាច់ត្រូវបន្តស្វែងយល់បន្ថែមទៀត ពីបញ្ហាប្រឈមនានា ដែលកំពុងកើតមានឡើង ដោយសារការប្រែប្រួលគុណភាពបរិស្ថាន ជាអាទិ៍រួមមានៈ ការកើនឡើងកំដៅភពផែនដី, បាតុភូតគ្រោះធម្មជាតិ, គ្រោះរាំងស្ងួត, គ្រោះទឹកជំនន់, ខ្យល់ព្យុះសង្ឃរា, ការខូតខាតប្រព័ន្ធអេកូឡូស៊ី, ការបាត់បង់ជីវៈចម្រុះ, ការកើតឡើងជំងឺដង្កាត់ប្លែកៗ បំផ្លាញជីវិតមនុស្ស សត្វ ដែលបញ្ហាទាំងនេះ មិនត្រឹមតែជះឥទ្ធិពលជាអវិជ្ជមានដល់ការអភិវឌ្ឍសង្គម- សេដ្ឋកិចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សុវត្ថិភាព និង សុខុមាលភាពសាធារណៈទៀតផង ។

ឆ្លៀតឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងនូវការកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន, ក្រសួង- ស្ថាប័ន, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់, អង្គការជាតិ-អន្តរជាតិ, វិស័យឯកជន, ព្រះសង្ឃ, ប្រជាពលរដ្ឋ និង សិស្សានុសិស្ស និស្សិតគ្រប់ភូមិសិក្សា ដែលបានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសស្រាក់សស្រាំ, ពុះពាររួមគ្នាយ៉ាងសកម្មនៅក្នុងយុទ្ធនាការ និង សកម្មភាពទាំងឡាយ ដើម្បីគោលដៅនៃការការពារបរិស្ថាន ក្នុងរយៈពេលកន្លងមក ហើយខ្ញុំសង្ឃឹមថា យើងនឹងបន្តកិចខិតខំប្រឹងប្រែងលើការងារនេះទៀត សម្រាប់ពេលអនាគតខាងមុខនេះ ។ ជាការពិត កិចខិតខំប្រឹងប្រែងនេះ នឹងបន្តរួមចំណែកពង្រឹងថែមទៀត នូវឆន្ទៈរបស់យើង និង ប្រជាជននៅលើភពផែនដីទាំងមូល ក្នុងបុព្វហេតុចូលរួមបង្ការ និង ទប់ស្កាត់គ្រោះមហន្តរាយនានា ឱ្យប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ធានានូវភាពសុខដុមរមនានៃការរស់នៅរបស់មនុស្ស ជាមួយនឹងបរិស្ថានបានយ៉ាងល្អប្រសើរ ។

ក្នុងឱកាសនេះដែរ ខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួមទាំងអស់ ទាំងភ្ញៀវជាតិ និង អន្តរជាតិ ដែលជាតំណាងក្រសួង- ស្ថាប័ននៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, តំណាងអង្គទូតនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា,

វិស័យឯកជន, គ្រឹះស្ថានសិក្សា, អង្គការសង្គមស៊ីវិល និង អ្នកចូលរួមទាំងអស់ នៅក្នុង **«វេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ»** នេះ ។

ជារួម **«វេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុ»** ត្រូវបានរៀបចំឡើងដោយទៀងទាត់ និង បានក្លាយជាព្រឹត្តិការណ៍ដ៏សំខាន់ ដែលផ្តល់ឱកាសឱ្យអ្នករៀបចំគោលនយោបាយ, អ្នកវិទ្យាសាស្ត្រ, ដៃគូអភិវឌ្ឍន៍ និង ប្រតិបត្តិករនានាមកជួបជុំគ្នា ដើម្បីបង្ហាញពីចំណេះដឹងថ្មីៗបំផុត អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ហើយចែករំលែកបទពិសោធន៍នៃផលប៉ះពាល់ទាំងនោះ ក្នុងគោលបំណងរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចគោលដៅអភិវឌ្ឍសង្គម- សេដ្ឋកិច្ចរបស់យើង នៅក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុនេះ ។ ជាក់ស្តែង វេទិកានេះនឹងផ្តល់លទ្ធភាពឱ្យយើងរួមគ្នាបន្តពិនិត្យមើលវឌ្ឍនភាព ដែលយើងសម្រេចបានចាប់តាំងពីវេទិកាជាតិលើកទី ២ កាលពីឆ្នាំ ២០១១ មកទល់បច្ចុប្បន្ននេះ និង ដើម្បីរួមចំណែកក្នុងការពិភាក្សាអំពីកិច្ចការជាអាទិភាពលើការប្រែប្រួលអាកាសធាតុនៅកម្ពុជាសម្រាប់រយៈពេលពី ៥ ទៅ ១០ ឆ្នាំខាងមុខទៀត ។

ជាការពិត ការប្រែប្រួលអាកាសធាតុ លែងជាអ្វីដែលស្ថិតនៅឆ្ងាយពីយើងទៀតហើយ ហើយកំពុងបង្កឥទ្ធិពលមកលើយើងទាំងអស់គ្នា ក្នុងពេលបច្ចុប្បន្ន និង ជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗបំផុត ដែលមនុស្សជាតិត្រូវប្រឈមនៅក្នុងសតវត្សរ៍ទី ២១ នេះ ដោយសារតែផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង ហើយមានវិសាលភាពកាន់តែធំជាងមុន ។ បើពិនិត្យតាមរបកគំហើញពីការស្រាវជ្រាវថ្មីៗ បានអះអាងយ៉ាងច្បាស់អំពីកំណើននៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ គឺកាន់តែខ្លាំងក្លា និង ញឹកញាប់ជាងមុន ខណៈដែលកំណើននៃការបពោញឧស្ម័នផ្ទះកញ្ចក់បានបន្តធ្វើឱ្យសីតុណ្ហភាពមធ្យមលើពិភពលោកកើនឡើងជាខ្លាំង ។ ជាក់ស្តែង នៅក្នុងឆ្នាំនេះ ពិភពលោកត្រូវបានសង្កេតឃើញថា កំហាប់ឧស្ម័នកាបូនិកនៅក្នុងបរិយាកាសកើនដល់ **៤០០ ភាគលាន** ដែលជាកម្រិតខ្ពស់បំផុតលើកដំបូង គិតចាប់តាំងពីពេលមានការវាស់ដោយប្រើប្រាស់ឧបករណ៍ទំនើបមក ។ នៅចំពោះមុខកំហាប់ឧស្ម័នកាបូនិច ក្នុងបរិយាកាសកម្រិតខ្ពស់បំផុតជាប្រវត្តិសាស្ត្រនេះ បានបង្ហាញថា យើងកំពុងឈានចូលទៅក្នុងស្ថានភាពមួយប្រកបដោយគ្រោះថ្នាក់ ។ ក្នុងនោះ តំបន់អាស៊ីប៉ាស៊ីហ្វិកបានពើបប្រទះនូវនិន្នាការ ដែលត្រូវប្រកាសអាសន្ននៃទឹកជំនន់, គ្រោះរាំងស្ងួត និង ព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតី ដែលកើតមានកាន់តែញឹកញាប់ និង ធ្ងន់ធ្ងរជាងមុន ជាពិសេសក្នុងអំឡុងនៃទសវត្សរ៍ចុងក្រោយនេះ ។ លើសពីនេះទៀត ភាពងាយរងគ្រោះនៃទឹកជំនន់នៅអាស៊ីនឹងបន្តកើនឡើង ហើយរហូតដល់ឆ្នាំ ២០២៥ ប្រជាជនច្រើនជាង ៤១០ លាននាក់ ដែលតំណាងឱ្យលើសពី ៨៥% នៃសេដ្ឋកិច្ចពិភពលោក ត្រូវប្រឈមនឹងហានិភ័យនៃការជន់លិចនៅតាមតំបន់ឆ្នេរ ដោយសារប្រឈមនឹងផលប៉ះពាល់នៃព្យុះស៊ីក្លូន និង តំបន់ទំនាបលិចទឹក ដែលងាយពើបប្រទះនឹងព្យុះទីហ្វុង ។ គ្រោះមហន្តរាយជាញឹកញាប់ទាំងនេះ រួមផ្សំជាមួយឥទ្ធិពលដទៃទៀត ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ ដូចជាការជ្រាបចូលនៃទឹកប្រៃនៅតាមតំបន់ឆ្នេរ ឬផលប៉ះពាល់បណ្តាលពីសត្វចង្រៃ និង ការរាតត្បាតនៃជំងឺបានធ្វើឱ្យការប្រែប្រួលអាកាសធាតុ ក្លាយជាបញ្ហាប្រឈម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ។ ទន្ទឹមនេះទឹកជំនន់នាពេលថ្មីៗនេះ នៅកម្ពុជាក៏បានបង្កឱ្យមានការបាត់បង់អាយុជីវិតមនុស្ស, ផលប៉ះពាល់ដល់ដំណាំកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធ និង ការចិញ្ចឹមជីវិតរបស់ប្រជាជននៅសហគមន៍ ដែលបញ្ហានេះ ជាភស្តុតាងថ្មីបន្ថែមទៀត បង្ហាញពីសញ្ញាបន្ទាន់ និង ភាពធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុនេះ ។

ដោយសារផលប៉ះពាល់ទាំងអស់នេះ យើងអាចនិយាយបានមួយបែបទៀតថា ***«ការប្រែប្រួលអាកាសធាតុបានក្លាយជាបញ្ហាប្រឈមជាយុទ្ធសាស្ត្រមួយក្នុងការអភិវឌ្ឍ ហើយទាមទារឱ្យមានការយកចិត្តទុកដាក់រួមគ្នាជាបន្ទាន់»*** ។ ហើយរិតតែសំខាន់ជាងនេះទៀត ***«បញ្ហានេះ តម្រូវឱ្យយើងត្រូវរួមគ្នាធ្វើសកម្មភាពជាបន្ទាន់ ក្នុងការកសាងគោលនយោបាយអាកាសធាតុសមស្របមួយ សម្រាប់ឆ្លើយតប ទាំងក្នុងកម្រិតមូលដ្ឋាន កម្រិតតំបន់ និង កម្រិតពិភពលោក»*** ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

ជារួម យើងទាំងអស់គ្នាបានដឹងហើយថា ការប្រែប្រួលបរិស្ថានភពផែនដី ជាបញ្ហាដែលកើតមានយ៉ាងពិតប្រាកដ ហើយយើងមិនអាចបដិសេធ ឬ នៅតែធ្វើមិនដឹងមិនឮ និង មិនអើពើបានទេ ។ ជាក់ស្តែង ការគ្រប់គ្រងបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាប្រឈមមួយទៀត សម្រាប់ចីរភាពនៃកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គមកម្ពុជា ក្នុងនោះ មានការបញ្ចេញចោលយ៉ាងសន្ធឹកសន្ធាប់នូវឧស្ម័នផ្ទះកញ្ចក់ ជាពិសេសឧស្ម័នកាបូនិច ដោយសារសម្ពាធពីកំណើនប្រជាជន, ចរនែនគរូបនីយកម្ម, វិបុលកម្ម និង ប្រពលកម្មកសិកម្ម ក៏ដូចជាការអភិវឌ្ឍវិស័យដឹកជញ្ជូន, ថាមពល និង វិស័យដទៃទៀត ។ ជាការពិត បញ្ហានេះមិនមែនយើងទើបតែយកចិត្តទុកដាក់ក្នុងពេលនេះនោះទេ ជាក់ស្តែង យើងបានធ្វើកិច្ចការច្រើនណាស់ហើយ នាពេលកន្លងមកនេះ ។ ក្នុងនោះ យើងបានអនុវត្តនូវអនុសាសន៍នានា ពីវេទិកាជាតិលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានរៀបចំឡើងកាលពីឆ្នាំ ២០១១ ដែលសកម្មភាពនេះ គឺជាភស្តុតាងបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលបណ្តាលមកពីការប្រែប្រួល អាកាសធាតុ ។

តាមរយៈនេះ កម្ពុជាក៏បានកសាងគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាកិច្ចការសំខាន់បំផុត ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និង សមត្ថភាពបច្ចេកទេសអន្តរវិស័យ ព្រមទាំងពហុជំនាញចាំបាច់ សម្រាប់កំណត់វិធានការ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ទន្ទឹមនេះ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅគ្រប់លំដាប់ថ្នាក់ ហើយបានរួមចំណែកយ៉ាងសកម្មនៅក្នុងកិច្ចប្រឹងប្រែង ទាំងនៅថ្នាក់តំបន់ និង អន្តរជាតិ សម្រាប់ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនេះ ។ ជាមួយគ្នានេះ យើងបានបង្កើតស្ថាប័ន និង វិធានការនានា រួមមានការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ, ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ជាដើម ។ កិច្ចការទាំងអស់នេះ គឺជាជំហានដ៏សំខាន់មួយ ហើយកម្ពុជានឹងបន្តដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ក្នុងគោលដៅ **អភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅក្រោយ ឆ្នាំ ២០១៥** ព្រមទាំងសមាហរណកម្មការងារនេះទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងនានាផងដែរ ។

ចំពោះមុខនេះ កម្ពុជាក៏បានដាក់ចេញវិធានការ និង សកម្មភាពជាក់លាក់ ដែលទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង ការអភិវឌ្ឍបៃតង ដែលការងារទាំងនេះ បានឆ្លុះបញ្ចាំងក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** របស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង យើងបាន និង កំពុងជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌ **«គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង»** និង **«ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០»** តាមរយៈការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និង

យន្តការ សម្រាប់ការធ្វើពាណិជ្ជកម្មកាបូន, ការពង្រឹងសមត្ថភាព, ការរៀបចំ និង អនុវត្តវិធានការ សម្រាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្នែកបរិស្ថាន ដូចជា ការទូទាត់កម្រៃបរិស្ថាន និង មូលនិធិបរិស្ថាន, ការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមទាំងជីវៈចម្រុះ, តំបន់ផ្ទៃរងទឹកភ្លៀង និង តំបន់ដីសើម ព្រមទាំងការពង្រឹងយន្តការតាមដាន និង ត្រួតពិនិត្យបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ី ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ក្នុងស្មារតីលើកកម្ពស់អនុវត្តការងារនេះ ឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង កាន់តែស៊ីជម្រៅ ខ្ញុំសូមជំរុញឱ្យក្រសួង- ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍ទាំងអស់ ធ្វើការពិចារណាជាលក្ខណៈប្រព័ន្ធអំពីការងារប្រែប្រួលអាកាសធាតុ នៅពេលលើកផែនការអន្តរាគមន៍លើការងារអភិវឌ្ឍ ដើម្បីធានាថា ការចំណាយវនិយោគនានា មានប្រសិទ្ធភាព និង ផ្តល់ផលក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុនេះ ។ ក្នុងនោះ យើងត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យខ្លាំងថែមទៀត លើការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ ដូចជាថាមពលវារីអគ្គិសនី, សំណល់កំដៅពីឧស្សាហកម្ម, សំណល់កសិកម្ម និង សំណល់ពីការចិញ្ចឹមសត្វ ជាដើម ។ ទន្ទឹមនេះ យើងក៏ត្រូវបន្តអនុវត្តនូវគំនិតផ្តួចផ្តើមការអភិវឌ្ឍបៃតងជាតិនៅកម្ពុជា ដើម្បីគាំទ្របន្ថែមទៀតដល់ការអភិវឌ្ឍប្រកបដោយចីរភាព ។ ក្នុងនោះដែរ យើងត្រូវបន្តយកចិត្តទុកដាក់លើការអនុវត្តបណ្តាគម្រោងយន្តការអភិវឌ្ឍស្អាត, ការជំរុញយុទ្ធនាការសន្សំសំចៃថាមពលអគ្គិសនី និង ប្រេងឥន្ធនៈ, សកម្មភាពការពារ និង អភិរក្សព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ, ព្រៃបម្រុង និង ព្រៃការពារ ជាដើម ។

ម្យ៉ាងទៀត ខ្ញុំយល់ថា ការអនុវត្តកម្មវិធីយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និង ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក៏មានសារៈសំខាន់ណាស់ដែរ ដើម្បីលើកទឹកចិត្តឱ្យមានការរួមចំណែកទាំងអស់គ្នា ។ ដូច្នេះ ដើម្បីសម្រេចការងារនេះបាន ទាមទារឱ្យមានកិចសហការជិតស្និទ្ធរវាងសកលវិទ្យាល័យ, មជ្ឈមណ្ឌលស្រាវជ្រាវ, ក្រសួង-ស្ថាប័ននានានៃរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ក្នុងការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីសិក្សា និង កម្មវិធីស្រាវជ្រាវ ហើយបង្កើតនូវយន្តការនានាសម្រាប់ផ្លាស់ប្តូរចំណេះដឹងទាំងអស់នោះ ដែលជាមូលដ្ឋានសំខាន់ ដល់ការរៀបចំគោលនយោបាយ ។ ប្រការនេះ នឹងជួយធានាបានថា គោលនយោបាយ និងផែនការការងារប្រែប្រួលអាកាសធាតុ របស់យើងនឹងត្រូវបានកសាងឡើង និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដោយផ្អែកលើចំណេះដឹងដែលមាន និង លទ្ធផលនៃការស្រាវជ្រាវមួយដែលអាចទុកចិត្តបាន ។

ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យក្រសួងអប់រំ យុវជន និង កីឡា គួរពិនិត្យពិចារណាដាក់បញ្ចូលមុខវិជ្ជាការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីអប់រំ និង បណ្តុះបណ្តាលនានា ទាំងកម្មវិធីសិក្សាក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តបង្កើតបរិយាកាសអំណោយផល និង លើកទឹកចិត្ត សម្រាប់ការចូលរួមរបសវិស័យឯកជន នៅក្នុងការវិនិយោគ ដែលនឹងជួយដោះស្រាយដល់ការងារប្រែប្រួលអាកាសធាតុ ទាំងលើវិធានការបន្សុាំ និង ការកាត់បន្ថយការបំពុលឧស្ម័នផ្ទះកញ្ចក់ ជាដើម ។

ប្រការសំខាន់មួយទៀត ដែលត្រូវផ្តោតការយកចិត្តទុកដាក់ គឺនៅពេលដែលកម្រិតហិរញ្ញប្បទានកើនឡើង ចំនួនច្រើននៃវិធីសាស្ត្រ និង មធ្យោបាយផ្តល់ខុសៗគ្នា នឹងបង្កើតឱ្យមានចំណាយពាក់ព័ន្ធខ្ពស់ ក៏ដូចជាភាពខ្វះចន្លោះ និង ភាពត្រួតលើគ្នា ដែលធ្វើឱ្យកិចខិតខំប្រឹងប្រែងរបស់យើងក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ មានប្រសិទ្ធភាពទាប

និង ផ្តល់ផលកម្រិតទាប ។ ដូច្នេះ ដើម្បីឱ្យវិធានការរបស់យើងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុផ្តល់លទ្ធផលជាទ្រង់ទ្រាយធំទៅតាមការរំពឹងទុកនោះចាំបាច់ត្រូវឈានជាបណ្តើរៗចេញពីគំរូនៃការអនុវត្តគម្រោងដាច់ដោយឡែកពីគ្នា ទៅរកអភិក្រមកម្មវិធី, ការប្រមូលផ្តុំមូលនិធិ និង ទីបំផុត គឺការគាំទ្រថវិកា ។ ក្នុងស្មារតីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងផែនការ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវសហការគ្នាជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំនូវវិធានការដែលងាកចេញពីគម្រោងដែលមានលក្ខណៈដាច់ពីគ្នា និង ការកសាងផែនការប្រែប្រួលអាកាសធាតុដាច់ដោយឡែកពីគ្នា ទៅរកសមាហរណកម្មការងារប្រែប្រួលអាកាសធាតុ ក្នុងដំណើរការថវិកា និង ការកសាងផែនការជាទៀងទាត់របស់យើង ។ ជាមួយនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏មានតួនាទីគន្លឹះក្នុងការចរចាជាមួយម្ចាស់ជំនួយនីមួយៗ ដើម្បីធានាថា កម្មវិធីរបស់ដៃគូអភិវឌ្ឍន៍នានា ត្រូវបានពិនិត្យជាលក្ខណៈប្រព័ន្ធនៅក្នុងក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ ហើយការពិចារណាអំពីការប្រែប្រួលអាកាសធាតុត្រូវតែបានដាក់បញ្ចូលទៅក្នុងកម្មវិធីទាំងនោះ នៅក្នុងករណីដែលមានការពាក់ព័ន្ធ ។

ជាមួយគ្នានេះ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និង លេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ ត្រូវមានភារកិច្ចកៀរគរ និង សម្របសម្រួលភាពជាដៃគូ សម្រាប់ការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនេះ ឱ្យកាន់តែសកម្មក្លៀវក្លាថែមទៀត ។ ជារួម គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ មិនត្រឹមតែដើរតួជាអ្នកផ្តល់យោបល់លើការងារអន្តរវិស័យដល់ក្រសួង និង ស្ថាប័ននានា នៃរាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែគឺជាអ្នកសម្របសម្រួលភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធពីខាងក្រៅ និង ពិនិត្យ តាមដាន និង វាយតម្លៃអំពីការប្រែប្រួលអាកាសធាតុទៀតផង ។ ក្នុងអនាគតដ៏ខ្លីខាងមុខនេះ សម្រាប់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែ-ប្រួលអាកាសធាតុ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចុះបញ្ជី និង បានការទទួលស្គាល់ជាអង្គភាពអនុវត្តនៅថ្នាក់ជាតិ នៅក្នុងក្របខណ្ឌមូលនិធិបន្សាំ និង បន្ទាប់មកមូលនិធិអាកាសធាតុបៃតង ដើម្បីឱ្យកម្ពុជាអាចមានសិទ្ធិទទួលបានហិរញ្ញវត្ថុអាកាសធាតុពិភពលោកដោយផ្ទាល់ ។ ទន្ទឹមនេះ យើងត្រូវផ្តល់ការគាំទ្រដល់ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ, ជនបង្គោលបច្ចេកទេស និង ក្រុមការងារប្រែប្រួលអាកាសធាតុនៅតាមក្រសួង- ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យពួកគេអាចបំពេញតួនាទីជាអ្នកជំនាញខាងការប្រែប្រួលអាកាសធាតុ នៅក្នុងក្រសួង- ស្ថាប័នរបស់ខ្លួន និង ផ្តល់យោបល់បច្ចេកទេសដល់សមាជិកនានា នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

ជារួម កម្ពុជាគាំទ្រទាំងស្រុងនូវការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិដោយផ្អែកលើគោលការណ៍សំខាន់ៗជាមូលដ្ឋាន គឺ ***ទទួលខុសត្រូវរួមគ្នា ប៉ុន្តែ ក្នុងកម្រិតផ្សេងគ្នា*** តាមសមត្ថភាពរៀងៗខ្លួន និង តម្រូវការដោយឡែក ចំពោះស្ថានភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេស ដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ។ ពិតមែនតែសមត្ថភាព និង ធនធានមានកម្រិត ក៏ប៉ុន្តែកម្ពុជាបានប្តេជ្ញាក្នុងឆន្ទៈនយោបាយខ្ពស់ ក្នុងការត្រៀមខ្លួន និង រួមចំណែកជានិច្ចក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល

ក្នុងការទទួលខុសត្រូវចំពោះជោគវាសនានៃមនុស្សជាតិ ក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយឈរលើស្មារតីនៃគោលការណ៍ចំបងៗរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

ក្នុងស្មារតីនេះ ខ្ញុំយល់ថា **វេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ** នេះ នឹងផល់នូវកាលានុវត្តភាពដ៏កម្រ សម្រាប់ការពិភាក្សាលើបញ្ហាជាច្រើន ដូចជា វិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ, ការចរចាអន្តរជាតិ, មេរៀននានា ដែលទទួលបានមកទល់បចប្បន្ន, យុទ្ធសាស្ត្ររបស់យើងសម្រាប់អនាគត, ការគ្រប់គ្រងចំណេះដឹង, ការស្រាវជ្រាវ និង ការចាត់ចែងហិរញ្ញប្បទាន លើការងារគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ។ ខ្ញុំសង្ឃឹមថា ឯកឧតម លោកជំទាវ លោក លោកស្រី ពិតជាទទួលបានអត្ថប្រយោជន៍ពីការពិភាក្សានានា ជាមួយប្រតិបត្តិករទាំងឡាយ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ហើយខ្ញុំរំពឹងថា យើងនឹងទទួលបានអនុសាសន៍ជាច្រើនផងដែរ ពីវេទិកានេះ ដើម្បីជាប្រយោជន៍សម្រាប់គាំទ្រកម្ពុជា ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាត ឆ្ពោះទៅការកសាងសង្គមមួយដែលបៃតង, បពោញកាបូនតិច, ធន់នឹងការប្រែប្រួលអាកាសធាតុ, មានសមធម៌ និង មានភាពសុខដុមរវាងការរស់នៅរបស់មនុស្ស និង បរិស្ថាន ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថែមទៀតថា នៅក្នុងអាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀត លើកិចការពារបរិស្ថាន ដែលជាវិធានការដ៏ចាំបាច់បំផុត ហើយចាត់ទុកនិរន្តរភាពបរិស្ថានជាអាទិភាពនាំផ្លូវដ៏ត្រឹមត្រូវ សម្រាប់យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និង ការលុបបំបាត់ភាពក្រីក្រ ។ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍបៃតងជាតិ ដែលអាចពង្រឹងនូវកំណើនសេដ្ឋកិច, ការប្រើប្រាស់, ការផលិត និង ធុរកិច ដែលមានលក្ខណៈបៃតង ដើម្បីរក្សាតុល្យភាពនៃការអភិវឌ្ឍឱ្យប្រកបដោយចីរភាពលើទិដ្ឋភាពធំទាំងបួន គឺ ***សង្គម វប្បធម៌ បរិស្ថាន និង សេដ្ឋកិច*** ។

នៅទីបពាប់នេះ ជាមួយនឹងការប្រកាសបើក ***«វេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ និង ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា»*** នៅពេលនេះ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អង្គវេទិកាទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ ***អាយុ វណ្ណៈ សុខៈ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរគុណ !***